# ឧបសម្ព័ន្ធទី ១ "សេចក្តីបញ្ញត្តអំពីការកិច្ច ទសាលភាពនៃការងារ"

**ATTACHMENT 1 – TERMS OF REFERENCE**

**The Wildlife Conservation Society**

**WCS Cambodia Program**

*****

| | | |
|---|---|---|
| Name | : | ---------------------------- |
| Position | : | Driver |
| Project | : | DTRA Project |
| Location | : | Phnom Penh |
| Report to | : | IT and Admin Officer |

---

## តួនាទី

- បើកបរជូនបុគ្គលិកអង្គការ បុគ្គលិករដ្ឋាភិបាល អ្នកប្រឹក្សាយោបល់ និងភ្ញៀវ ទៅកាន់គោលដៅ ទូទាំងប្រទេសកម្ពុជា គ្រប់ស្ថានភាពផ្លូវ ដោយគួរសម រាក់ទាក់ ជួយលើក និងជញ្ជូន សម្ភារៈដាក់ក្នុង និងចេញពីរថយន្ត។
- បើកបរដោយការយកចិត្តទុកដាក់ខ្ពស់ រួមមានទាំងការផ្លាស់ប្តូរល្បឿននៅពេលបើកបរតាមស្ថានភាពផ្លូវ ដើម្បីធានាសុវត្ថិភាពដល់យានយន្ត អ្នកដំណើរ អ្នកផ្សេងទៀតដែលធ្វើដំណើរតាមដងផ្លូវ និងធានាថាអ្នកដំណើរទាំងអស់ពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព
- ធានាថា សម្ភារៈសង្គ្រោះបឋម ត្រូវបានរៀបចំ និងរក្សាទុកក្នុងយានយន្ត មុនពេលចេញដំណើរទៅខេត្ត/ទីកន្លែងណាមួយ( ពេលមកវិញត្រូវយកកាបូបសង្គ្រោះបឋមអោយ អ្នកគ្រប់គ្រង )
- ជួយការងារផ្នែកសន្តិសុខ និងសុវត្ថិភាពនៅពេលចាំបាច់ (នៅពេលដែលអ្នកយាម អវត្តមាន ឬសុំច្បាប់ឈប់សម្រាក )
- ទទួលខុសត្រូវលើសៀវភៅកំណត់ត្រាការប្រើប្រាស់ និងថែទាំយានយន្ត ដោយកត់ត្រាលំអិតពីការប្រើប្រាស់ប្រេងម៉ាស៊ូត និងប្រេងឥន្ធនៈ និងរបាយការណ៍ ដែលទាក់ទងនឹងការថែទាំយានយន្ត
- ទទួលខុសត្រូវត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ និងធានាថារថយន្តត្រូវបានថែទាំជាប្រចាំ (រួមមាន ប្រេងឥន្ធនៈ ប្រេងម៉ាស៊ីន ហ្គាស អំពូល កង់ អាគុយ ស៊ីផ្លេ ឧបករណ៍ សម្ភារៈ ហ្វ្រាំង បង្អួច កញ្ចក់ និងលាងសម្អាតយានយន្តទាំងខាងក្នុងនិងខាងក្រៅ អោយបានស្អាតជាប្រចាំ )
- ជូនដំណឹងដល់អ្នកគ្រប់គ្រងអំពីការខូចខាត និងតម្រូវការថែទាំនិងជួសជុលយានយន្ត និងជួយសម្របសម្រួលក្នុងការជួសជុលយានយន្តជាមួយយានដ្ឋានដែលអង្គការកំណត់
- អនុវត្តរាល់ភារកិច្ចផ្សេងទៀតដែល ចាត់តាំងដោយអ្នកគ្រប់គ្រង ប្រធានគម្រោង ឬទីប្រឹក្សាបច្ចេកទេស
- ជួយរៀបចំ កាលវិភាគនៃការថែទាំយានយន្ត
- ជួយការងាររដ្ឋបាល ដូចជា រត់សំបុត្រ ប្រមូលឯកសារពីក្រសួងមន្ទីរពាក់ព័ន្ធ ថតចម្លងឯកសារ
- ត្រូវទាក់ទងក្រុមហ៊ុនធានារ៉ាប់រងហ្វតតេជាបន្ទាន់ រាល់ពេលមានគ្រោះថ្នាក់កើតឡើង
- បំពេញភារកិច្ចដទៃទៀតតាមការតម្រូវពីអ្នកគ្រប់គ្រងរបស់ខ្លួន ។

## លក្ខណៈសម្បត្តិ និងបទពិសោធន៍ដែលតម្រូវចាំបាច់

- បញ្ចប់មធ្យមសិក្សាបឋមភូមិ ឬទុតិយភូមិ
- មានបណ្ណ័បើកបរកម្ពុជា( យ៉ាងហោចណាស់ ប្រភេទ B)
- មានបទពិសោធន៍ជាអ្នកបើកបរ យ៉ាងតិច ២ ឆ្នាំ ជាមួយរដ្ឋាភិបាល ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល ឬអង្គការអន្តរជាតិ ក្នុងប្រទេសកម្ពុជា
- មានបទពិសោធន៍ក្នុងការបើកបរផ្លូវឆ្ងាយនិងផ្លូវលំបាកដោយប្រើប្រាស់យានយន្ត 4x4
- មានបទពិសោធន៍ក្នុងការបើកបរនៅតំបន់ព្រៃនិងជនបទនៃប្រទេសកម្ពុជាអំឡុងពេលរដូវវស្សានិង រដូវប្រាំង
- មានសមត្ថភាពចេះអាន សរសេរ និងប្រាស្រ័យទាក់ទងជាភាសាខ្មែរ និងភាសាអង់គ្លេស ( តិចតួច )
- មានចំណេះដឹងមូលដ្ឋានទាក់ទងនឹងមាស៊ីនយានយន្ត

## ការងារ និងការប្រាស្រ័យទាក់ទង

ទំនាក់ទំនងជាមួយបុគ្គលិកគម្រោងទាំងអស់ខាងផ្នែករដ្ឋបាល គណនេយ្យ មន្ត្រីក្រសួងបរិស្ថាន និង ប្រធានផ្នែកដែលពាក់ព័ន្ធ។ ព្រមទាំងរាល់កិច្ចការ ការចាត់តាំងភារកិច្ច និង/ឬតួនាទីដទៃទៀត ដែលអង្គការ WCS ឬគណៈគ្រប់គ្រងរបស់ អង្គការ WCS អាចនឹងចាត់តាំង ឬណែនាំឱ្យបំពេញក្នុងដំណើរការនៃប្រតិបត្តិការ របស់អង្គការ WCS ដែលអាចមានកិច្ចការ ការចាត់តាំង ភារកិច្ច និង/ឬតួនាទីនានា ផ្សេងពីការរៀបរាប់ខាងលើ។